ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
ROYAL UNIVERSITY OF LAW AND ECONOMICS

## កិច្ចការស្រាវជ្រាវ

ប្រធានបទ ៖ ទម្រង់អាជីវកម្ម
មុខវិជ្ជា ៖ សហគ្រិនភាព
បង្រៀនដោយ ៖ សាស្ត្រាចារ្យ ព្រុំ ទេវី

ស្រាវជ្រាវដោយនិស្សិត D3C01

| | |
|---|---|
| ១. ខៀវ ដានីន | ២. គុណ សុខចាន់មុនី |
| ៣. ទូច រស្មី | ៤. លឹម គឹមចេម |
| ៥. វេន វិទូ | ៦. ស៊ិន សៀងហៃ |
| ៧. ស៊ាន លីយ៉ា | ៨. ស៊ឹន នីតសា |

ឆ្នាំសិក្សា ២០២៤~២០២៥

# អារម្ភកថា

សូមស្វាគមន៍មិត្តនិស្សិត ប្រិយមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវជាទីរាប់អាន!

យើងខ្ញុំ ជានិស្សិតឆ្នាំទី៣ ជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំមានសេចក្ដីសប្បាយរីករាយណាស់ ដែលទទួលបានការយកចិត្តទុកដាក់ពីអ្នកគ្រូ **ព្រុំ ទេវី** ក្នុងការពន្យល់យ៉ាងក្បោះក្បាយ និងដឹកនាំយ៉ាងម៉ត់ចត់ក្នុងកិច្ចការស្រាវជ្រាវនេះ ជាហេតុធ្វើឱ្យយើងខ្ញុំទាំងអស់អាចចងក្រងសៀវភៅនេះឡើងបាន ដើម្បីចែករំលែកដល់ប្រិយមិត្តទាំងឡាយ។

ក្នុងការចងក្រងសៀវភៅនេះ យើងខ្ញុំបានបកស្រាយនូវបញ្ហាមួយចំនួនតូចទៅតាមលទ្ធភាព ដែលយើងខ្ញុំបានខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវកន្លងមក និងតាមឯកសារយោងខ្លះៗ ដែលមាននៅក្នុងបណ្ណាល័យ បណ្ដាញសង្គម និងគេហទំព័រផ្សេងៗតែប៉ុណ្ណោះ។ យើងខ្ញុំសង្ឃឹមថាសៀវភៅនេះនឹងក្លាយជាមូលដ្ឋានគ្រឹះមួយដែលជួយបង្ហាញពីវិធីសាស្ត្រមួយចំនួនសម្រាប់កែលំអខ្លឹមសារឈានទៅរកភាពលំអិតនៃប្រធានបទផងដែរ។

បន្ថែមពីនេះ យើងខ្ញុំក៏រីករាយចាំទទួលនូវការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកអ្នកគ្រូសាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ នូវរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនាទាំងពាក្យពេចន៍ ឃ្លាឃ្លោង វេយ្យាករណ៍ អក្ខរក្រម ដើម្បីជាមតិស្ថាបនា កែលំអសៀវភៅនេះឱ្យកាន់តែល្អប្រសើរ និងប្រកបដោយសុក្រិតភាព។

ជាចុងក្រោយ យើងខ្ញុំសូមគោរពជូនពរយ៉ាងស្មោះសរដល់ប្រិយមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ទទួលបាននូវពរទាំងបួន សម្បត្តិទាំងបី អរិយទ្រព្យទាំងប្រាំពីរ និងមានសេចក្ដីសុខ សំណាងល្អគ្រប់ពេលវេលា ទទួលជោគជ័យលើការសិក្សា និងសម្រេចនូវគោលបំណងដែលបានបន់ប៉ងគ្រប់គ្នាកុំបីខានឡើយ។

# មាតិកា

I. កំណត់ឈ្មោះអាជីវកម្ម....1
II. កំណត់សិទ្ធិអាជីវកម្ម ....2
២.១ និយមន័យ ....2
២.២.សមាជិកសហកម្មសិទ្ធករ....2
២.៣.ការដាក់ទុន ....2
III. ទីតាំងអាជីវកម្ម ....3
IV. កំណត់ដំណើរការចុះបញ្ជីអាជីវកម្ម....4
V. ចក្ខុវិស័យ និងគោលដៅ....5
៥.១.ចក្ខុវិស័យ....5
៥.២.គោលដៅ ....6
៥.៣. បេសកកម្ម ....6
VI. សេចក្ដីសន្និដ្ឋាន

# I. កំណាត់ឈ្មោះអាជីវកម្ម




## ❖ និមិត្តសញ្ញាដើមឈើ

ដើមឈើធំដែលមានឫស និងមែកដែលអាចមើលឃើញជានិមិត្តរូបៈ

- ➢ កំណើន និងស្ថិរភាព
- ➢ ទំនាក់ទំនងជាមួយធម្មជាតិ
- ➢ និរន្តរភាព និងគ្រឿងផ្សំធម្មជាតិ
- ➢ រាងមូលរបស់ដើមឈើបង្ហាញពីតុល្យភាព និងភាពពេញលេញ។

## ❖ ស្លឹកបៃតង និងឫស

ពណ៌បៃតងតំណាងឱ្យសុខភាព ភាពស្រស់ស្រាយ និងបរិស្ថាន។ ឫសគល់បង្ហាញពីទំនាក់ទំនងយ៉ាងស៊ីជម្រៅទៅនឹងប្រពៃណី ឬផែនដី ដែលអាចបង្ហាញថា ផលិតផលប្រើរូបមន្តបុរាណ ឬប្រភពធម្មជាតិ។

ការរក្សានូវអាហារដែលជាបតិភណ្ឌពីដូនតាបន្សល់ទុកមក ឬការចាប់ផ្តើមថ្មីនៃផលិតផលថ្មី តែរក្សាគ្រឹះនៃម្ហូបពីដូនតា។

# II. កំណត់សិទ្ធិអាជីវកម្ម

## ២.១ និយមន័យ

កម្មសិទ្ធិបញ្ញក្នុងអាជីវកកម្មគឺជា សិទ្ធផ្លូវច្បាប់លើការច្នៃប្រឌិតផ្ទាល់ខ្លួន ឬការច្នៃប្រឌិតរបស់អាជីវកម្ម ដែលអាចប្រើប្រាស់ដើម្បីការពារសម្គាល់ និងរកចំណេញពីសម្បត្តិចំណេះដឹងនោះ។ កម្មសិទ្ធិបញ្ញា ៤ប្រភេទរួមមានដូចជា សិទ្ធិអ្នកនិពន្ធ ពាណិជ្ជនាម ប្រកាសនីយបត្រតក្កកម្មនិង និង ការសម្ងាត់ពាណិជ្ជកម្ម។ ចំពោះអាជីវកម្មរបស់ពួកយើង ជាប្រភេទអាជីវកម្មពាណិជ្ជនាម ដោយពួកយើងបានបង្កើតឈ្មោះ ស្លាកសញ្ញាបង្ហាញពីអត្តសញ្ញាណរបស់ផលិតផលពួកយើងផងដែរ។ ហើយការចុះបញ្ជីសញ្ញាសម្គាល់ពាណិជ្ជកម្មនេះផងដែរ។គឺជាជំហានសំខាន់មួយដើម្បីការពារអត្តសញ្ញាណអាជីវកម្មរបស់ពួកយើងមិនឲ្យគេក្លែងបន្លំប្រើឬចម្លង។ដោយការចុះបញ្ជីអាចដាក់ពាក្យតាមរយៈ ប្រតិបត្តិការនៃការចុះបញ្ជីកម្មសិទ្ធិបញ្ញា ដែលគ្រប់គ្រងដោយ ក្រសួងពាណិជ្ជកម្ម។

យោងតាមច្បាប់ស្តីពីសហគ្រាសសភាពាណិជ្ជកម្ម និងច្បាប់ស្តីពិវិសោធនកម្មស្តីពីសហគ្រាសពាណិជ្ជកម្មរបស់ព្រះរាជាណាចក្រកម្ពុជា គេបានចែងចែកសហគ្រាសជាប្រភេទផ្សេងៗរួមមាន សហគ្រាសឯកបុគ្គល ក្រុមហ៊ុនសហកម្មសិទ្ធិ និងក្រុមហ៊ុនមូលធន។ ប៉ុន្តែនៅក្នុងក្រុមហ៊ុនសហកម្មសិទ្ធមាន២ប្រភេទបន្ថែមទៀតមានដូចជាក្រុមហ៊ុនសហកម្មសិទ្ធទូទៅ និងក្រុមហ៊ុនសហកម្មសិទ្ធមានកម្រិតហើយក្នុងអាជីវកម្មរបស់ពួកយើងជាក្រុមហ៊ុនសហកម្មសិទ្ធទូទៅ ព្រោះអាជីវកម្មមួយនេះបង្កើតឡើងពីកិច្ចសន្យារវាងសមាជិកជាច្រើននាក់ដែលបានដាក់បញ្ចូលរួមគ្នានូវទ្រព្យសម្បត្តិ ចំណេះដឹងដើម្បីបង្កើតអាជីវកម្មមួយនេះរួមគ្នាក្នុងគោលបំណងរកប្រាក់ចំណេញ ហើយសមាជិកពួកយើងទាំងអស់គ្នាជាសហកម្មសិទ្ធិករទូទៅ។

## ២.២.សមាជិកសហកម្មសិទ្ធករ

សមាជិកសហកម្មសិទ្ធករយើងទាំអស់មានចំនួន ៦ នាក់ហើយសហការគ្នាដើម្បីប្រកបអាជីវកម្មមួយកែច្នៃគ្រាប់ស្វាយចន្ទីរួមគ្នាក្នុងការស្វែងរកប្រាក់ចំណេញ និងមានសិទ្ធិទៅគ្រប់គ្រងទទួលខុសត្រូវចំពោះបំណុលនឹងកាតព្វកិច្ចរបស់ក្រុមហ៊ុនដោយផ្ទាល់។

## ២.៣.ការដាក់ទុន

ការដាក់របស់សមាជិកក្រុមបានដាក់ជាសាច់ប្រាក់ចំនួនសរុបសាមសិបម៉ឺនដុល្លារ (៣០០០០០ដុល្លា) ដើម្បីជាដើមទុនចាប់ផ្តើមអាជីវកម្មមួយនេះ ហើយការដាក់ទុកនេះត្រូវបានចែងក្នុងកិច្ចសន្យាសហកម្មសិទ្ធិផងដែរ។ ការដាក់ទុននេះផងដែរវាជាមូលដ្ឋានដ៏សំខាន់នៃការបង្កើតសហកម្មព្រោះបានបញ្ជាក់ពីសិទ្ធិ ភារកិច្ច និងការចូលរួមរបស់សមាជិកនីមួយៗ។ លើសពីនេះដែរទំនាក់ទំនងជាមួយអតិថិជនទាក់ទងទៅ

នឹងវិធីដែលសហកម្មសិទ្ធិទូទៅមានភារកិច្ចចំពោះអតិថិជននៅពេលអនុវត្តន៍អាជីវកម្ម ប្រសិនបើអាជីវកម្មនេះបាត់បង់តណទានឬក្ស័យធន ហើយបង្កការខូចខាតដល់អតិថិជនសមាជិកទាំងអស់ត្រូវទទួលខុសត្រូវដោយផ្ទាល់។

## III. ទីតាំងអាជីវកម្ម

ភូមិបែកអន្លូងជាតំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការបង្កើត និងអភិវឌ្ឍអាជីវកម្មផលិតកម្មអាហារ និងសម្ភារៈផ្សេងៗ។ ទីតាំងនេះមានទាំងធនធានធម្មជាតិគ្រប់គ្រាន់កម្លាំងពលកម្មស្រាប់ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ ជាមួយនឹងទីតាំងស្ថិតនៅក្នុងខេត្តកំពង់ចាម ដែលមានការភ្ជាប់ដឹកជញ្ជូនងាយស្រួល ទីតាំងនេះក្លាយជាជម្រើសដ៏ល្អសម្រាប់អ្នកចាប់ផ្តើម និងអ្នកចង់ពង្រីកអាជីវកម្ម។

### ក. ធនធានដី និងសម្ភារៈ

- ដីមានសម្បូរបែប អាចប្រើសម្រាប់ការផលិត និងការកសិកម្ម។
- តម្លៃដីនៅតែសមរម្យ អាចចាប់ផ្តើមអាជីវកម្មដោយការវិនិយោគទាប។

### ខ. កម្លាំងពលកម្ម

- មានកម្មករមានបទពិសោធន៍ក្នុងការផលិត និងដំណើរការអាហារសម្រន់ (snack)។
- ពលកម្មមានភាពរឹងមាំ និងអាចបណ្តុះបណ្តាលបន្ថែមបានងាយ។

### គ. ហេដ្ឋារចនាសម្ព័ន្ធ

- មានការតភ្ជាប់អគ្គិសនី (EDC) និងប្រព័ន្ធទឹកស្អាត។
- ងាយស្រួលរកគ្រឿងជាតុដើមពីទីផ្សារក្នុងស្រុក និងជិតខេត្តជាប់ខាង។
- ការចែកចាយ និងដឹកជញ្ជូន (Distribution & Logistics)

### ឃ. ទីផ្សារគោលដៅ

- ខេត្តកំពង់ចាមមានទីផ្សារធំៗ និងហាងលក់រាយជាច្រើន។
- ជិតទីផ្សារក្នុងខេត្ត និងទីផ្សារក្នុងរាជធានីភ្នំពេញ។

### ង. ផ្លូវ និងប្រព័ន្ធដឹកជញ្ជូន

- មានផ្លូវសមស្របសម្រាប់រថយន្ត និងរថយន្តដឹកទំនិញធំៗ។
- អាចដឹកជញ្ជូនទៅទីផ្សារផ្សេងៗបានលឿន។

### ច. ហានិភ័យ និងការគ្រប់គ្រង

- ក្នុងរដូវវស្សាអាចមានបញ្ហាផ្លូវលំបាក ប៉ុន្តែទំនាក់ទំនងដឹកជញ្ជូននៅតែមានប្រសិទ្ធភាព។
- ការអភិវឌ្ឍអាជីវកម្ម និងទីផ្សារ (Business Development & Market)

**ឆ. ផ្សារ និងហាងលក់**

- មានផ្សារ និងហាងលក់ក្នុងតំបន់ និងជិតខេត្ត។
- ងាយស្រួលក្នុងការផ្សព្វផ្សាយ និងបង្កើតភាពជាដៃគូជាមួយអ្នកលក់។

**ជ. ការបង្កើតឱកាស**

- អាចប្រើទីតាំងនេះសម្រាប់ផលិតផលថ្មី និងការពង្រីកផលិតកម្ម។
- មានសក្ដានុពលក្នុងការបង្កើតទីផ្សារបន្ថែមនៅក្នុងតំបន់។
- ទីតាំងភូមិបែកអន្លង់ ឃុំអារក្សត្នោតស្រុកស្ទឹងត្រង់ គឺជាជម្រើសល្អសម្រាប់អាជីវកម្មផលិត និងចែកចាយអាហារ និងសម្ភារៈផ្សេងៗ។ ជាមួយនឹងធនធានធម្មជាតិ កម្លាំងពលកម្មស្រាប់ និងការភ្ជាប់ដឹកជញ្ជូនល្អ ទីតាំងនេះអាចផ្ដល់អត្ថប្រយោជន៍យ៉ាងច្រើនសម្រាប់អ្នកវិនិយោគ។

# IV. តំណាក់ដំណើរការចុះបញ្ជីអាជីវកម្ម

## ក. ក្រុមហ៊ុនសហកម្មសិទ្ធ

ដើម្បីអាចចុះបញ្ជីក្រុមហ៊ុនសហកម្មសិទ្ធិទាំងអស់ត្រូវមកកាន់ការិយាល័យក្នុងការចុះបញ្ជីពាណិជ្ជកម្មក្រសួងពាណិជ្ជកម្ម លើកលែងតែក្នុងករណីដែលមានសាខាចុះបញ្ជី ពាណិជ្ជកម្មនៅក្នុង ខេត្តរបស់ខ្លួន។ ដើម្បីធ្វើការចុះបញ្ជីពាណិជ្ជកម្ម ដែលក្នុងករណីនេះ ក្រុមហ៊ុនសហកម្មសិទ្ធិ ត្រូវដាក់ពាក្យសុំទៅសាខា។

## ខ. ឈ្មោះក្រុមហ៊ុន

ការពិនិត្យនាមករណ៍របស់ក្រុមហ៊ុនសហកម្មសិទ្ធិនៅនាយកដ្ឋានចុះ បញ្ជីពាណិជ្ជកម្មនៃក្រសួងពាណិជ្ជកម្ម ។ ការសម្រេចចិត្តដ៏សំខាន់ជាដំបូង គឺការជ្រើសរើសនាមករណ៍សម្រាប់អាជីវកម្មរបស់អ្នក។ នាមករណ៍អាជីវកម្មដ៏មានប្រសិទ្ធភាពត្រូវមានទំនាក់ទំនងទៅនឹងផលិតផល ឬសេវាកម្មរបស់អ្នក ហើយងាយអាន ងាយប្រកប និងងាយចងចាំ។ ហើយដំណើរការនេះចំណាយពេលប្រហែលជា ៥ថ្ងៃធ្វើការដើម្បីពិនិត្យឯកសារ និងចេញវិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម។ ប្រសិនបើពាក្យសុំត្រូវបានធ្វើឡើងនៅសាខាចុះបញ្ជី ពាណិជ្ជកម្មខេត្តវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មបណ្ដោះអាសន្ននឹង ត្រូវចេញ ជូនក្នុងកំឡុងពេល ១០ ថ្ងៃ។ វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្មបណ្ដោះអាសន្ននេះមានសុពលភាព រយៈពេល ៣០ថ្ងៃ ហើយវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្មផ្លូវការនឹងត្រូវចេញជូនក្នុង កំឡុងរយៈពេលសុពលភាពនោះ។

## គ. វិញ្ញាបនបត្រ

គោលបំណងរបស់ទញ្ញាបនបត្រពីក្រសួងសុខាភិបាលបញ្ជាក់ពីអនាម័យ និងសុវត្ថិភាពផលិតផល (ចំណីអាហារ) ។

❖ **ការស្នើសុំវិញ្ញាបនបត្រ**

សំណុំឯកសារស្នើសុំវិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ ឬវិញ្ញាបនបត្រ អនាម័យផលិតផលចំណីអាហារ មានដូចខាងក្រោម៖

- ពាក្យស្នើសុំ (មានគំរូ)
- លិខិតអនុញ្ញាតបើកគ្រឹះស្ថានផលិតរោងចក្រផលិត ឬក្រុមហ៊ុននាំចូល នាំចេញផលិតផលចំណីអាហារដែលមានការបញ្ជាក់ពីក្រសួង ស្ថានប័ន ឬពីអាជ្ញាធរពាក់ព័ន្ធ
- ប័ណ្ណប៉ាតង់ដែលស្ថិតក្នុងសុពលភាព (ចំពោះផលិតផលក្នុងស្រុក អនុវត្តតាមខ្លឹមសារ លេខ៥០២ សហវ.ប្រក ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ)
- វិញ្ញាបនបត្របញ្ជាក់គោលការណ៍អនុវត្តអនាម័យល្អ (GMP) ឬ HACCP Certificate ឬ ISO - 22000 ឬវិញ្ញាបនបត្រសមមូល-វិញ្ញាបនបត្រវិភាគពីរោងចក្រផលិត(Certificate of Analysis)
- វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ ឬវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ (Free Sales Certificate / Health Certificate) ពីប្រទេសផលិត ឬប្រទេសដែលកំពុងដាក់លក់ផលិតផលចំណីអាហារនោះ (មិនអនុវត្តចំពោះផលិតផលក្នុងស្រុកទេ)
- គំរូសាកផលិតផលចំនួន ៥ ឯកតា (Samples: 5 units)
- វិញ្ញាបនបត្របញ្ជាក់ការដាក់លក់ផលិតផលចំណីអាហារ (Certificate of Free Sales)
- និងវិញ្ញាបនបត្រអនាម័យផលិតផលចំណីអាហារ (Health Certificate) មានសុពលភាពរយៈពេល០១ឆ្នាំ។
- ក្រសួងសុខាភិបាលនឹងផ្តល់វិញ្ញាបនបត្រទាំងពីរខាងលើជូនគ្រឹះស្ថានផលិត រោងចក្រផលិតឬក្រុមហ៊ុននាំចេញនាំចូលផលិតផលចំណីអាហារក្នុងរយៈពេល៣០ថ្ងៃ (ថ្ងៃធ្វើការ) បន្ទាប់ពីទទួលបានឯកសារគ្រប់គ្រាន់។

# V. ចក្ខុវិស័យ និងគោលដៅ

## ៥.១.ចក្ខុវិស័យ

ដើម្បីក្លាយជាក្រុមហ៊ុនដឹកនាំក្នុងការកែច្នៃគ្រាប់ធញ្ញជាតិនៅកម្ពុជា ដោយផ្តល់ផលិតផលដែលមានគុណភាពខ្ពស់ មានអនាម័យ ដែលអាចបំពេញតម្រូវការទីផ្សារក្នុងស្រុក និងអន្តរជាតិបាន។ ខណៈដែលជួយលើកស្ទួយជីវភាពកសិករនិងសហគមន៍ជនបទ។ បំផុសឲ្យគ្រាប់ស្វាយចន្ទីកម្ពុជា ក្លាយជាផលិតផលសហសម្រស់រវាងសុខភាព អាហារូបត្ថម្ភ និងវប្បធម៌ ដែលអាចប្រកួតប្រជែងលើទីផ្សារប្រកបដោយចីរភាព។

ម្យ៉ាងវិញទៀតយើងគឺនឹង បង្កើតអនាគតបៃតងជាមួយធញ្ញជាតិខ្មែរ ដោយធ្វើឲ្យគ្រាប់ធញ្ញជាតិកម្ពុជាស្គាល់នៅទូទាំងពិភពលោក និងជាគន្លងភ្លឺសម្រាប់កសិករខ្មែរ តាមរយៈការកែច្នៃទំនើប។

## ៥.២.គោលដៅ

គោលបំណងដែលយើងបង្កើតឲ្យមានជាគម្រោងនេះកំណត់គឺបង្កើតសហគ្រាសកែច្នៃពោលគឺធ្វើយាងណា ដើម្បីកែច្នៃផលិតនៅក្នុងស្រុកឲ្យទៅជារបស់ហូប ជាផលិតផលដែលមានគុណភាព និងស្តង់ដារអនាម័យ ដែលផ្លាស់ប្តូរពីផលិតផលដើមទៅជាផលិតផលសម្រេច សម្រាប់បរិភោគ និងដាក់លក់ហើយជាផលិតផលសម្រេចដែលមានគុណភាពខ្ពស់ និងថែមទាំងជាប្រភេទអាហារសុខភាពដ៏ល្អផងដែរ។

ជាពិសេសផ្តោតទៅលើ គ្រាប់ធញ្ញជាតិ ដែលជាផលិតផលក្នុងស្រុក ។ ដោយអាចផ្តល់ឱកាសការងារដល់ប្រជាជនក្នុងតំបន់ និងជួយដល់កសិករដែលផលិតធញ្ញជាតិឲ្យមានទីផ្សារយ៉ាងសម្បូរបែប និងមានភាពងាយស្រួលដល់កសិករប្រកបអាជីវកម្មប្រភេទនេះ ថែមទាំងផ្តល់ការងារដល់សហគមន៍ក្នុងតំបន់ទៀតផង។ ដែលបង្កើតផលិតផលក្នុងស្រុកដែលមានគុណភាពស្មើ ឬលើសពីផលិតផលនាំចូល ។ដើម្បីបង្កើនការពឹងផ្អែកលើទំនិញក្នុងស្រុក ម្យ៉ាវិញទៀតយើងអាចជម្រុញការប្រើប្រាស់ផលិតផលក្នុងស្រុកកាន់តែច្រើនឡើង និងធ្វើការនាំចេញឈានជើងចូលទៅក្នុងទីផ្សារអន្តរជាតិ។ ដែលគោលដៅនេះចែកជា៣ដំណាក់កាល

១.រយៈពេលខ្លី ៖ផលិតផលិតផលដែលមានគុណភាពល្អ និងអនាម័យបង្កើតការទទួលស្គាល់ម៉ាកក្នុងស្រុក ១ ឆ្នាំ។

២.រយៈពេលមធ្យមៈជាការជ្រៀតចូលទីផ្សារប្រទេសជិតខាងបន្ថែមប្រភេទផលិតផល និងអនុវត្ត ISO/HACCP ៣ ឆ្នាំ។

៣.និងរយៈពេលវែង៖ គឺដើម្បីក្លាយជាម៉ាកស្វាយចន្ទីល្បីនៅលើឆាកអន្តរជាតិនិង បង្កើតការងារចីរភាពសម្រាប់សហគមន៍ ៥ ឆ្នាំឡើង។

## ៥.៣. បេសកកម្ម

ក្រុមហ៊ុន Snack dream នឹងបង្កើតអាហារសម្រន់ដែលមានគុណភាពខ្ពស់និងសុខភាពល្អ ដើម្បីផ្តល់នូវបទពិសោធអាហារដែលល្អបំផុតសម្រាប់អតិថិជន។ យើងនឹងបន្តផ្តល់ជូននូវអាហារសម្រន់ដែលមានសារធាតុចិញ្ចឹម និងរសជាតិឆ្ងាញ់។

## VI. សេចក្ដីសន្និដ្ឋាន

អាជីវកម្មនេះមានគោលបំណងកែច្នៃ និងចែកចាយគ្រាប់ស្វាយចន្ទីដែលមានគុណភាពខ្ពស់ សុវត្ថិភាព អនាម័យ និងមានតម្លៃបន្ថែមដោយប្រើប្រាស់បច្ចេកវិទ្យាទំនើប និងគោរពស្តង់ដារអនាម័យអាហារ។ ក្រុមហ៊ុននឹងសហការជាមួយកសិករក្នុងស្រុក ដើម្បីទិញវត្ថុធាតុដើមតាមតម្លៃសមរម្យ និងលើកស្ទួយការផលិតឲ្យមានគុណភាពស្របតាមស្តង់ដារ។ ដើម្បីក្លាយជាក្រុមហ៊ុនកែច្នៃគ្រាប់ស្វាយចន្ទីដែលមានឈ្មោះល្បីលំដាប់អន្តរជាតិ ផ្តល់ផលិតផលមានគុណភាពខ្ពស់ សុវត្ថិភាព អនាម័យ និងមានតម្លៃបន្ថែម ដើម្បីលើកស្ទួយកសិករ និងសហគមន៍កម្ពុជា។